**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# ញត្តិថ្កោលទោស

ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ព្រមទាំងបុគ្គលិកទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមធ្វើការប្រឆាំងដាច់ខាត និងថ្កោលទោសយ៉ាងដាច់អហង្ការចំពោះការអំពាវនាវរបស់ទណ្ឌិត សម រង្ស៊ី តាមរយៈឃ្លីបវីដេអូមួយដែលបានផ្សព្វផ្សាយជាសាធារណៈកាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២២ ប្រកាសទៅកាន់ប្រជាពលរដ្ឋកម្ពុជា និងកងកម្លាំងប្រដាប់អាវុធថា៖ **"ត្រូវមានការផ្លាស់ប្តូរនៅកម្ពុជា ក្នុងឆ្នាំ២០២៣"** ដែលពាក្យសម្តីទាំងនេះ គឺជាការញុះញង់ និងមានចេតនាឧក្រិដ្ឋ ប៉ុនប៉ងបង្កចលនាប្រជាពលរដ្ឋ និងកងកម្លាំងប្រដាប់អាវុធ ឱ្យប្រឆាំង បះបោរផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ក្នុងឆ្នាំ២០២៣។ ការអំពាវនាវរបស់ទណ្ឌិត សម រង្ស៊ី គឺជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរមកលើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ធ្វើឡើងក្នុងចេតនាបំផ្លាញឆន្ទៈរបស់ប្រជាពលរដ្ឋជាម្ចាស់ឆ្នោត បំផ្លាញនូវសុខសន្តិភាព ព្រមទាំងសេចក្តីសុខសប្បាយ ភាពសុខដុមរមនារបស់ប្រជាជនកម្ពុជាទាំងមូល ដែលទង្វើរបស់បុគ្គលរូបនេះមិនអាចអត់ឱនឱ្យបានឡើយ។ មិនត្រឹមតែប៉ុណ្ណោះ បុគ្គលរូបនេះក៏បាននិយាយប្រមាថដោយប្រើពាក្យសម្តីអសីលធម៌យ៉ាងធ្ងន់ធ្ងរមកលើ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលជាអ្នកមានគុណបំណាច់ឧត្តុង្គឧត្តមមិនអាចកាត់ថ្លៃបានចំពោះជាតិមាតុភូមិ និងប្រជាជនកម្ពុជា ហើយក៏ជាមគ្គុទ្ទេសក៍ដ៏អង់អាចក្លាហានដែលបានលះបង់តស៊ូប្តូរជីវិតក្នុងការរំដោះប្រទេសពីរបបខ្មែរក្រហមដ៏សាហាវយង់ឃ្នង និងព្រៃផ្សៃបំផុត នាំមកនូវសន្តិភាព សិទ្ធិសេរីភាព ឯកភាពជាតិ កិត្យានុភាពជាតិ និងវិបុលភាពសង្គមកម្ពុជាដូចសព្វថ្ងៃនេះ។

ក្នុងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកទាំងអស់ នៃក្រសួងមុខងារសាធារណៈ យើងខ្ញុំទាំងអស់គ្នា សូមធ្វើការប្រកាសជាឱឡារិក ប្តេជ្ញាចូលរួមជាមួយរាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ការពារឱ្យបានដាច់ខាតនូវរដ្ឋធម្មនុញ្ញ សន្តិភាព និងវិបុលភាពសង្គមកម្ពុជា ជាពិសេសការពារដាច់ខាតនូវរាជរដ្ឋាភិបាលស្របច្បាប់ និងការពារ **សម្តេចតេជោ ព្រមទាំងក្រុមគ្រួសារ** ជានិច្ចទោះស្ថិតក្នុងតម្លៃណាក៏ដោយ។

ឆ្លៀតក្នុងឱកាសដ៏ប្រសើរថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នាសូមលើកហត្ថប្រណម្យឧទ្ទិសបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក តេជះបារមីគ្រប់ទិសទី ព្រមទាំងទេវតាថែរក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមជួយប្រោះព្រំថែរក្សា ការពារ **សម្តេចតេជោ** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំង **បុត្រា បុត្រី ចៅប្រុស ចៅស្រី** សូមមានសុខភាពល្អបរិបូរណ៍ ជន្មាយុយឺនយូរ ព្រមទាំងទទួលបានសព្វសាធុការពរជ័យ សិរីសួស្តី ជ័យមង្គល វិបុលសុខគ្រប់ប្រការ និងសមប្រកបតែនឹងព្រះពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃអង្គារ ៨រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២